ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



ភាគទី ៦

ផ្សាយដោយ "[illegible]"

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## សម្រាប់ទេសន៍

ទី ៦

## កណ្ឌចូឡ្លពន

ប្រដាប់ដោយគាថា ៣៥

បោះពុម្ពលើកទី ១
ចំនួន ១.០០០ ច្បាប់

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥០៩

Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

ទី ៦

## កណ្ឌាចូឡពន

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឯវំ ចេតបុត្តោ ព្រាហ្មណំ ភោជេត្វា ចាបេយ្យស្សត្ថាយ តស្ស មធុនោ តុម្ពញ្ច បក្កមិគសត្ថិញ្ច ទត្វា មគ្គេ ឋបេត្វា ទក្ខិណាហត្ថំ ឧក្ខិបិត្វា មហាសត្តស្ស វសនោកាសំ អាចិក្ខន្តោ អាហ ។ ចេតបុត្តោ រីឯចេតបុត្រដ៏ជាត្រកូលព្រានព្រៃ សុត្វា លុះបានស្តាប់សំដីជូជកពោលពាក្យកុហកមុសាវាទ ថាជារាជទូតព្រះបាទស្រីសញ្ជ័យប្រើមកអារាធនាព្រះបាទវេស្សន្តរ បវរពោធិសត្វ ទៅគ្រប់គ្រងរាជសម្បត្តិនាជេតុត្តរនគរដូច្នោះហើយ ព្រាហ្មណំ ភោជេត្វា ទើបឲ្យជូជកព្រឹទ្ធាចារ្យ បរិភោគអាហារផងដ៏បរិបូណ៌ ពុំឃ្លូរឡើយ ទត្វា ទើបឲ្យទឹកឃ្មុំ នូវបាយ និងសាច់ទ្រាយឆ្អើរ ដ៏មានរសពិសា ប្រយោជន៍ឲ្យជាស្បៀងអាហារ តាជូជកនឹងឆីលាងជីវិត ទៅឯមុខ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយផ្លូវព្រៃហេមពាន្តហោង ទក្ខិណាហត្ថំ ឧក្ខិបិត្វា ទើបលើកហត្ថាងស្តាំ ចង្អុលប្រាប់ផ្លូវទៅដោយជើងគិរី ដ៏ជាឋានស្ងាត់ជ្រងំសឹងតែព្រឹក្សា ទើបសូត្រជាបាទព្រះគាថាដូច្នេះថា ៖

ឯស សេលោ មហាព្រហ្មេ បព្វតោ គន្ធមាទនោ
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ ។
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ ។
ឯតេ នីលា បទិស្សន្តិ នានាផលធរា ទុមា
ឧគ្គតា អព្ភកូដាវ នីលា អញ្ជនបព្វតា ។
ធវស្សកណ្ណា ខទិរា សាលា ផន្ទនមាលុវា
សម្បវេធន្តិ វាតេន សកឹ បីតាវ មាណវា ។
ឧបរិ ទុមបរិយាយេសុ សង្គីតិយោវ សុយ្យរេ
នជ្ជុហា កោកិលា សង្ឃា សម្បតន្តិ ទុមា ទុមំ ។
អវ្ហយន្តេវ គច្ឆន្តំ សាខាបត្តសមីរិតា

Websites: WatKhemaraRatanaram.org or WatKhmers.org

រមយន្តេ អាគន្តុំ មោទយន្តិ និវាសធំ ។
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ
ជាវន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសព្ចធំ ។
ចម្មវាសី ឆមា សេតិ ជាតវេធំ មនស្សតីតិ ។

មហាព្រហ្មេ ហៃតាព្រាហ្មណ៍ព្រឹទ្ធាចារ្យ ឯស មោះ ឯសោ បព្វតោ រីភ្នំឯណោះ សេលោ មោះ សេលមយោ តាជីអើយ សឹងតែថ្មដាដាសពាសនូវថ្មបាយក្រៀម សឹងធំៗ ជាដុំខៀវ សល្អ ប្រុះឆ្លុះ យល់ឆ្ងាយស្វាយក្រហមខៀវលឿងទាំង ៥ ពណ៌ ល្អប្លែក ៗ ងងឹតអ័ព្ទមេឃ បែកជាផ្សេង ភ្នំនោះឯងលោកសន្មត ហៅឈ្មោះគន្ធមាទន៍បពិត ដ៏មាននូវគន្ធពិដោរប្រសើរ សឹងឈើក្រអូបល្វេងល្វើយខ្វះខ្វាយសព្វសាយនៅព្រៃប្រទេស វេស្សន្តរោ រាជា រីឯព្រះបាទស្រីវេស្សន្តរ បរំពោធិសត្វ នូវវត្នរាជមទ្រី ព្រះរាជបុត្រីបុត្រា ក៏សឹងជាឧត្តមបរមសុខទាំង ៤ ព្រះអង្គ ចេញមកទ្រង់ព្រតជាតាបសនៅក្នុងពនាល័យ អើតាជីអើយ ចូរព្រះស្តែងប្រែមុខទៅត្រង់ផ្លូវ ដែលយើងចង្អុលប្រាប់ ក៏នឹងបានប្រសព្វនឹងព្រះអច្ចុតឫសី អ្នកតែងកាន់ទំពក់

Websites: WatKhemaraRatanaram.org or WatKhmers.org

បេះផលាផល តម្កល់ដាក់លើកញ្ជើសង្រែក ហើយអ្នករែកលើព្រះ
អង្សា ចងជដារុំព្រះកេសតាមភេទឥសី ដណ្តប់ស្បៃស្បែកខ្លាទាំង
ក្រចក សម្បុរច្រាលរិលរង់ អ្នកទ្រង់សំបកឈើតាងព្រះពស្ត្រស្អាត
ក្រវាត់ស្បូវភ្លាំង ក្រាលក្រងស្លឹកឈើរងជាទីបន្ទំ អ្នកប្រណម្យនមស្ការ
កងអគ្គី តាមប្រពៃណីអំពីបុរាណ អ្នកគង់នៅនាឋាននោះឯងហោង
ព្រហ្មេ ហៃតាជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ឃតេ ឧមា រីឯឈើផង
ទាំងឡាយសងខាងផ្លូវ ប្រកបនីទៅនូវផលាផល ដោយពណ៌ទីទៃ ៗ
ខ្លះខ្ទីចាស់ទុំស្រគាល ពុំដឹងបើនឹងគណនា ឧត្តតា សឹងដ៏វែងវៀវល
លៀវខ្ពស់ ៗ ឪលា ស្លឹកដ៏ខៀវស្រស់ដូចអញ្ចូនបពិត ពុំដឹងកំណត់
ប្រាប់តាព្រឹទ្ធាចារ្យ នូវអស់ព្រឹក្សាសឹងដ៏មានមែកបែកសាខា ត្រសាយ
ត្រសុំ ជវស្សកណ្ណា ជាដើមគឺត្របែកត្រសេកស្ពឺ ស្ពង់ចុងពុំរៀវ ស្លឹក
ខៀវដូចអ្នករចនា ខទិរា គគីរ ឆាំឆា គុយ គ ឧទុម្ពរ សឹងដ៏ដុះស្រោង
ស្រោងសងខាងផ្លូវ នឹងទៅគន្ធមាទន៍គិរី ។ តាជីអើយ នឹងពណ៌នាង
ផ្កាក្តាំងងាចម្ប៉ាចំប៉ី មាលតី មហាហង្ស ត្រយង់ យុថ្កា ច្បារន្ទួនស្រី ពុំ
ដឹងបើនឹងស្រដីរាប់ឲ្យគ្រប់ឈ្មុយឈ្ងប់សព្វទិសា កេសររុះរោយដោយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដី ឯសន្លឹកខ្លះខ្ចី ខ្លះចាស់ ខ្លះទើបនឹងលាស់សន្លឹក ត្រូវខ្យល់បក់ត្រួយ
រញ្ជួយទៅមករកគ្នា ។ ឯវំ មាណវ ឧបមាបីដូចមាណព ពុំដែលផឹក
ស្រា សតិ បីតា ទើបតែនឹងបានប្រទះផឹកតែម្តង ក៏កម្រើកសរសៃ
សម្បុរជ្រួញច្រាញ ឲ្យជាស្រៀវស្រាញអង្រង់សិរសី វង្វេងស្មាតីខំតែ
ទប់ទល់ រីព្រឹក្សាផងមានឧបមាដូចមាណពនោះឯងហោង ។ ព្រហ្ម
ម្នាលព្រាហ្មណ៍អើយ ឯព្រៃខេត្តខេមព្រះហេមពាន្ត សឹងដ៏មាន
សំណាក់នៃបក្សាបក្សី តែងនឹងអាស្រ័យនៅសព្វវេលា ហើរនាវេហាស៍
យាសយំ ចុះមកទំដោយលង្វែកអ្នកមែកសាខា ខ្សៀវខ្សារដោយភាសា
ឰល្វេងល្វើយ សឹងតែសម្លេងពីរោះ ឥដ្ឋុវាហ រីបក្សីទាំងឡាយនោះ គឺ
ប៉ោលតោក ក្ងោក តាវៅ ស្វិតថៅ ចាកក្រពាក ចង្កៀលខ្សង ត្រយង
ត្រំ ត្លុម ស្វាំង ភ្ញាំង ឧកអក លលក សារិកា ឆ្លៀងរកអាហារសំឡេង
កង្កួច ត្រលួល បីដូចនូវតូរ្យតន្ត្រីត្រៃស័ង្ខរគាំងភេរី ពិណពាទ្យរងំសម
គ្នាទាំងសងខាងមគ្គានោះ តាជីអើយ មុខគួរស្រណោះពន់ប្រមាណ ។
សាខាបត្តសមីរិតា ហៃតាជូជកអើយ រីមែកនូវសន្លឹកឈើផងទាំង
ឡាយ បើព្រះពាយបក់មកត្រូវ សឹងដ៏ទន្ទងទៅមករកគ្នា ហាក់ដូច

Websites: WatKhemaraRatanaram.org or WatKhmers.org

មនុស្សម្នា ស្រែកដង្ហោយហៅនូវបុគ្គល ដែលដើរទៅមកទាំងឡាយ កើតមានសេចក្ដីសប្បាយអភិរម្យក្នុងប្រាណនៃបុគ្គល អ្នកបានដើរទៅមកនោះឯងហោង ។ ចេតបុត្តោ រឹងចេតបុត្រ ដ៏ជាត្រកូលព្រានព្រៃ នាកាលប្រស្រ័យពណ៌នា អំពីព្រះអាស្រមព្រះបរមពោធិសត្វ ក៏សូត្រជាបាទព្រះគាថាដូច្នេះថា ៖

អម្ពា កបិត្ថា បនសា សាលា ជម្ពូ វិភេទកា
ហរីតកី អាមលកា អស្សត្ថា ពទរានិ ច ។
ចារុតិម្ពរុក្ខា ចេត្ថ និគ្រោធា ច កបិត្ថនា
មធុមធុកា ថេវន្តិ នីចេ បក្កា ចុទុម្ពរា ។
បារេវតា ភវេយ្យា ច មុទ្ទិកា ច មធុត្ថិកា
មធុំ អនេលកំ តត្ថ សកមាទាយ ភុញ្ជរេ ។
អញ្ញេត្ថ បុប្ផិតា អម្ពា អញ្ញេ តិដ្ឋន្តិ ទោវិលា
អញ្ញេ អាមា ច បក្កា ច ភិង្គវណ្ណា តទូភយំ
អថេត្ថ ហេដ្ឋា បុរិសោ អម្ពបក្កានិ គណ្ហាតិ

Websites: WatKhemaraRatanaram.org or WatKhmers.org

អាមានិ ចេវ បក្កានិ វណ្ណគន្ធរសុត្តមា ។
អត្ថេវ មេ អច្ឆរិយំ ហិង្ការោ បដិភាតិ មំ
ទេវានមិវ អាវាសោ សោភតិ នន្ទនូបមោ ។
វិភេទកា នាឡិកេរា ខជ្ជុរីនំ ព្រហាវនេ
មាលាវ គន្ថិតា ឋន្តិ ធជគ្គានេវ ទិស្សរេ ។
នានាវណ្ណេហិ បុប្ផេហិ នភំ តារា ចិតាមិវ
កុដជី កុដ្ឋតគ្គរា បាដលិយោ ច បុប្ផិតា ។
បុន្នាគា គិរិបុន្នាគា កោវិឡារា ច បុប្ផិតា
ឧទ្ទាលកា សោមរុក្ខា អគរុភល្លិយា ពហូ
បុត្តជីវា ច កុក្កុធា អសនា ចេត្ថ បុប្ផិតា ។
កុដជា សលឡា នីបា កោសម្ពលពុជា ធវា
សាលា ច បុប្ផិតា តត្ថ បលាលខលសន្និភា ។
តស្សា វិទូរេ បោក្ខរណី ភូមិភាគេ មនោរមេ
បទុមុប្បលសញ្ឆន្នា ទេវានមិវ នន្ទនេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អថេត្ថ បុប្ផរសមត្តា      កោកិលា មញ្ជុភាណិកា
អភិនាទេន្តិ តំ វនំ      ឧតុសម្បុប្ផិតេ ទុមេ ។
ភស្សន្តិ មករន្ទេហិ      បោក្ខរេ បោក្ខរេ មធូ ។
អថេត្ថ វាតា វាយន្តិ      ទក្ខិណា អថ បច្ឆិមា
បទុមកិញ្ជក្ខរេណូហិ      ឱកិណ្ណោ ហោតិ អស្សមោ
ថូលា សិង្ឃាដកា ចេត្ថ      សសាទិយា បសាទិយា
មច្ឆកច្ឆបព្យា វិធា      ពហូ ចេត្ថ មុបយានកា
មធុំ ភិសេហិ សវតិ      ខីរំ សប្បិ មុឡាលិភិ ។
សុរភិ តំ វនំ វាតិ      នានាគន្ធសមេរិតំ
សម្មោទិតេវ គន្ធេន      បុប្ផសាខាហិ តំ វនំ
ភមរា បុប្ផគន្ធេន      សមន្តាមភិនាទិតា ។
អថេត្ថ សកុណា សន្តិ      នានាវណ្ណា ពហូ ទិជា
មោទន្តិ សហ ភរិយាហិ      អញ្ញមញ្ញំ បកូជិនោ ។
នន្ទិកា ជីវបុត្តា ច      ជីវបុត្តា បិយាចនោ

Websites: WatKhemaraRatanaram.org or WatKhmers.org

បិយា បុត្តា បិយា ឆទ្ទា    និជា ចោក្ខុរណីយកា
មាលាវ តន្ថិតា បន្តិ    ឆជក្កានេវ និស្សរេ ។
ណាណាវណ្ណេហិ បុប្ផេហិ    កុសលេហិ សុកន្ធិតា
យត្ថ វេស្សន្តរោ រាជា    សហ បុត្តេហិ សម្មតិ
ណាវេត្តោ ព្រាហ្មណាវណ្ណំ    អាសនញ្ចូ មសញ្ចដំ
ចម្មវាសី ឆមា សេតិ    ជាតវេទំ មនស្សតីតិ ។

ព្រហ្មេ  ហៃតាអាចារ្យអើយ ឯព្រៃព្រះហេមពាន្តនោះ ដ៏ប្រកបនីទៅនូវព្រៃធំ ព្រៃជង្គំ រពោះចន្លោះគុម្ពោតស្បាតញាតញឹក សោកម៉ោក សឹងច្រើនក្រៃអនេក រីអស់ព្រៃព្រឹក្សានោះ មានពណ៌ទីទៃៗ ពុំដឹងបើនឹងប្រាប់ តាជីអើយ យើងនឹងរាប់ឲ្យអស់សេចក្តី អម្ពាវីស្វាយព្រៃ ស្វាយស្រុក សឹងដ៏ដុះប្រកិត ទាំងក្រសាំងនូវខ្វិត ផ្លែដូចរំយោល រំដួល ពុទ្រា វិភេឧកា សម៉ ត្រៀលស្វា កន្ទួតព្រៃ កន្ទួតស្រុក ផ្លែដូចគេចាក់ គគរ ឧទម្ពរ ព្និល ព្នៅ បង្គា បង្គៅ មាក់ប៉ែន គូលែន សិរមាន់ ច័ន្ទន៍ មាក់បាត លាំងសាត ទុរេន មៀន ប្រដាក មាក់ប្រេង មាក់ប្រាង មាក់សាង មាក់ដោក ឪឡោក

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្ទឹងខ្វាស់ ដូងព្រះ ស្រទ្បៅ តាត្រៅ ត្រៀក ត្រាច ផ្តុកផ្អៀក អង្កាញ់ អង្កោល កណ្តោល កណ្តាក់ ចម្បក់ រាំងភ្នំ ស្រគំ ពង្រ ញ ព្រីង ព្រូស ជន្លួស ក្រកោះ លំពោះ ក្រវាន់ ច័ន្ទន៍ក្រស្នា ភេកា ការកេស ចេកទេស ត្រយង់សឹងដ៏ដុះហាង់ដោយមាគ៌ា ។ ចារុត្តិម្ពរុក្ខា មង្ឃុត ល្មុត សេដា ពុទ្រា ផ្នា ផ្នុង ដងអង្កាល់ អម្ពិល ទ្រមូង គ្រញូង ក្រទ្បាញ់ ឯផ្កានោះមិញដូចគេព្យូរជាក្លូរទាំងទង មជុមជុកា ភ្លូ ភ្លូង ទន្លាប់ ខ្លះ ក្តិប ខ្លះទុំ ផ្អែមលើសទឹកឃ្មុំ រង្វូស្កូរ បរិភោគសឹងដ៏មានរស មានដើម ពុំទាបពុំខ្ពស់ ល្មមតែឈោងបេះប្របេះឆីតាមចិត្តសប្បាយ ជេវន្តិ មុខគួរស្រណោះនឹងអស់ព្រឹក្សា សឹងតែផ្លែផ្កាច្រាសច្រាល ខ្លះ ស្រគាលខ្លះទុំ ដ៏មាននៅខាងព្រះបរមសាលានោះ ។ ព្រហ្មេ ហៃតាអាចារ្យអើយ កាទ្ទលិយោ រីចេក អំពៅ ត្រាវ ដំទ្បូង ដូង ស្លា ដុះនៅ សងខាងមាគ៌ាទៅឯមុខនោះ ចារវេតា មានទាំងចេកភ្លុក ចេកព្រៃ ចេកស្នែង សឹងដ៏ដុះឯងទាបៗ ដោយមាគ៌ា ចេកជ្វា ចេករាជសីហ៍ ផ្លែ វែងរទងៗ ស្ងួងអួសដោយដី ជារយ ជាពាន់ ចេកពងមាន់ ចេកអំបូង ខ្លះលេចត្រយូង ស្រគាល ទុំផ្អែមដូចទឹកឃ្មុំ ដ៏មាននៅខាងព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

អាស្រមនោះឯងហោង ។ ព្រហ្មៈ ហៃតាអាចារ្យអើយ នឹងពណ៌នាឯងព្រៃព្រឹក្សាច្រើនផ្សេងៗ ពុំដឹងបើនឹងរាប់ឲ្យគ្រប់ វិភេឧភា មានក្រស្នា ចូងច័ន្ទន៍ លំពាន់ ដីប្លី បញ្ចកាណី ក្លាំពាក់ ក្លាំពា ម្នាងសិលា ច័ន្ទន៍ស ច័ន្ទន៍ក្រហម ចាជលិយោ ការកេស ចេកទេស ចម្ប៉ា នូនស្រី មាលតី មហាហង្ស បុប្ផិតា ផ្កាសឹងដ៏រីករាយសន្ធឹកត្រសុំសាខា ហាក់ដូចមនុស្សម្នារៀបរណ្ដាប់ ។ អរិទ្ធេ ក៏មាននៅខាងព្រះអាស្រមនោះឯងហោង ។ មួយសោត ឯស្រះស្រង់ក៏សឹងដ៏បូនជ្រុងស្មើ រេះរាបមុំទាបខ្ពស់ដូចអ្នករចនា ទឹកថ្លាយង់យល់ដី មានផ្កាឧប្បល ចង្កុលណី លំចង់ស្បៀង្កុជ សឹងដ៏ដុះលាយលេចគ្នា មានផ្ការីករហង់ពេញក្នុងស្រះបោក្ខរណី ច្រើនក្រៃពន់ប្រមាណ មានហ្វូងមច្ឆាហែលរេរាទៅមករកគូជាដើមគឺ ប្លាមូ ប្លាម៉ា គុជ្រា អណ្ដែងងាំង គល់រាំង រាហូ ឆ្ដោ ផ្ទក់ ក្អុក ក្អី ក្រាយ ក្លាំងហាយ ក្លាំងហាត ស្លាត ដងខ្មែង ច្រកែង ថ្ពិន ក្មាន់ ទីពោ បង្កា បង្កង កំពឹស ចង្វាផង សឹងរកអាហារជាចំណីក៏មាននៅនាស្រះស្រីនេះឯងហោង ។ ព្រហ្មៈ ហៃតាព្រឹទ្ធាចារ្យអើយ យើងនឹងពណ៌នាឯងបក្សីបក្សាផងទាំងឡាយ ក៏សឹងហើរប្រញាយទៅមក ខ្លះ

ហើរទាបមកនាផែនដី ឆាបចំណីអាហារភស្តុផង យំកងរំពងនៅខាងអាស្រម សំឡេងរងំថ្វាយព្រះពរពុំដែលដាច់ខាតខានថា «បពិត្រព្រះបាទ សូមចំរើនសុខសួស្តី កុំបីមានទុក្ខសព្វទិវារាត្រី ឲ្យប្រកបនូវមហេសី បុត្រាបុត្រី ជាលីក្រស្នា សូមមានព្រះជន្មវស្សាយឺនយូរ សុខសួស្តី ដោយតេជៈបារមីចតុព្រហ្មវិហារ នៃព្រះអង្គទ្រង់ព្រះរាជសម្ភារនោះឯងហោង ។

ឯវំ ចេតបុត្តេន វេស្សន្តរស្ស វសនដ្ឋានេ អក្ខាតេ ជូជកោ បិតុស្សិត្វា បដិសណ្ឋារំ ករោន្តោ ឥមំ គាថមាហ ។ នាកាលចេតបុត្រព្រានព្រៃ ប្រស្រ័យពណ៌នា ប្រាប់ព្រឹក្សាដល់តាព្រឹទ្ធាចារ្យសព្វសេចក្តី តាជីក៏ត្រេកអរសោមនស្សា ក៏សូត្រជាបាទព្រះគាថា ដូច្នេះ

ឥទញ្ច មេ សត្តុភត្តំ មធុនា បដិសំយុតំ
មធុបិណ្ឌិកា ច សុកតាយោ សត្តុភត្តំ ទទាមិ តេតិ ។

ចេតបុត្ត ហៃចៅចេតបុត្រ ដ៏ជាត្រកូលព្រានព្រៃ ដ៏ជាក្នួយសំឡាញ់ អ្នកពិភ័ក្តិរក្សាទ្វារផ្លូវនឹងទៅអាស្រមបទ អ្នកប្រាប់ឲ្យមាដឹងប្រាកដ នូវដរបោះចន្លោះព្រៃ អើមាគាប់ចិត្តណាស់ហើយក្នួយ

Websites: WatKhemaraRatanaram.org or WatKhmers.org

សំឡាញ់មាអើយ មានឹងរកអ្វីតបស្នងសងគុណនោះ ពុំមានឡើយ ។ មានតែចំណីដែលដៃនាងអមិត្តតាបនា ដ៏ជាភរិយាសម្លាញ់មា នាងរៀបរណ្តាប់ឲ្យមក ទើបជូជកភើចយកថង់យាម មកបង្ហួតចេតបុត្រព្រានព្រៃ ។

តំ សុត្វា ចេតបុត្តោ អាហ ។ ក្សិណនោះ ចេតបុត្រព្រានព្រៃស្តាប់ពាក្យព្រាហ្មណ៍ហើយ ឆ្លើយថាដូច្នេះ ៖

តុយ្ហេវ សម្ពលំ ហោតុ    នាហំ ឥច្ឆាមិ សម្ពលំ
ឥតោបិ ព្រហ្មេ គណ្ហាហិ    គច្ឆ ព្រហ្មេ យថាសុខំ ។
អយំ ឯកបទី ឯតិ    ឧជុំ គច្ឆតិ អស្សមំ
ឥសីបិ អច្ចុតោ តត្ថ    បង្កទន្តោ រជស្សិរោ ។
ធារេន្តោ ព្រាហ្មណាវណ្ណំ    អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ    ជាតវេទំ នមស្សតិ
តំ ត្វំ គន្ត្វាន បុច្ឆស្សុ    សោ តេ មគ្គំ បវក្ខតីតិ ។

ហៃព្រាហ្មណ៍អើយ សដូវខៅតាក តានឹងឲ្យយើងភោក្តា ក៏យើងពុំប្រាថ្នាឡើយ ចូរយកជាស្បៀងលាងជីវិតទៅឯមុខ តាជូជក

Websites: WatKhemaraRatanaram.org or WatKhmers.org

អើយ រីផ្លូវនោះត្រង់ពុំវៀចពុំវង្វេង ទៅមុខទៀតជាផ្លូវចង្អៀត ចុះតែជើងអ្នកមួយដើរ ចូរតាកុំថប់ តានឹងបានប្រសព្វនឹងព្រះអច្ចុតឫសីបង្គ័ឧត្តោ ធ្មេញអ្នកសស្វាចដូចជាចាន ហើយមានរោមចង្កា ឯសិរសាដ៏ពេញនីទៅនូវល្អងធូលីដូចគេប្រឡាក់ អ្នកពាក់ស្បែកខ្លា ជានិច្ចកាលពុំដែលដាច់ខាន អ្នកសេយ្យាសន៍លើពសុធាតាងពូកព្រំ អ្នកបង្គំហោមពិធីតាមប្រពៃណីឥសីអំពីបុរាណ អ្នកគង់នៅនាឋាន នោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសូត្រនូវបាទព្រះគាថាដូច្នេះ ៖

ឥធំ សុត្វា ព្រហ្មពន្ធុ ចេតំ គត្វា បតត្ថិណំ
ឧតគ្គចិត្តោ បក្កាមិ យេនាសិ អច្ចុតោ ឥសីតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យ ក្នុងវដ្តសង្សារទាំងឡាយអើយ ព្រហ្មពន្ធុ រីតាព្រឹទ្ធាចារ្យដ៏ជាផៅពង្ស អ្នកហិនហោចប្រយោជន៍ចង់លោភលន់ បតត្ថិណំ គត្វា តាចាស់ជរាដើរប្រទក្សិណ ៣ ជុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេតបុត្រហើយ ឧគ្គចិត្តោ ពុំលង់ឡើយ តាជីមានចិត្តរីករាយ ស្រដីលាថា «ក្មួយសម្លាញ់អើយ ចូរអ្នកនៅឲ្យសប្បាយកុំបីមានទុក្ខ សោក រោគភ័យ ជរាព្យាធិ មានេះនឹងលាអ្នកទៅហើយ» ពុំលង់ឡើយ តាជីក៏យកសំពត់មកក្រវាត់ព័ទ្ធចង្កេះផង យកថង់មកដាក់លើស្មា ហត្ថាប្រវាចាប់ឈើច្រត់មកទប់ប្រាណ ដើរចេញអំពីឋាននោះទៅងងក់ៗ តាជីខំតែទប់ជំពប់ដួលខ្ទោក ថង់យោកដូចគេគ្រវាត់ ភ្លាត់ធ្លាក់ពីស្មា លាន់មាត់ថា ថុច្ចះ! ពះ ! ទប់ឲ្យបាន គិតស្មានថាជាឆ្កែវាដេញដូចអំពីមុននោះ ខំស្រែកគម្រោះគម្រើយបង្អើលថាឆ្កែ ៗ បែរមុខទៅមើល លុះពុំឃើញ ទើបតាចាស់ទំពែក នៅតែជាយគ្រែងកណ្តាល រលីងហ្មត់ យកឈើច្រត់មកផ្ទប់ដើរទៅតាមមាគ៌ា អស្សមោឆ្ពោះសំដៅទៅអាស្រម នៃមហាអច្ចុតឫសី អហោសិ មាននៅយត្ថ បទេសេ នាឋានប្រទេសណា បត្តោមិ តាជីក៏ដើរសំដៅទៅ តំបទេសំ កាន់ឋានលំនៅប្រទេសនោះឯងហោង ។

ចូឡវណ្ណនា និដ្ឋិតា បពិត្រអើយ អាត្មាភាពសំដែង ថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតកកណ្ឌចូឡពន ដ៏ប្រដាប់

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រដានូវគាថា ៣៥ គាថា ជាគ្រឿងប្រដាប់សតិបញ្ញា នៃឧបាសកឧបាសិកា ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ។៚

(ចប់កណ្ឌាចូឡពនទី ៦ តែប៉ុណ្ណេះ)

---

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**លោកគ្រូអាចារ្យ ឈឹម សំបូរ**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង